**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**កំពង់ផែស្វយ័តភ្នំពេញ**

លេខ......២៣៤..............ក. ស. ក.

ថ្ងៃព្រហស្បតិ៍ ៣កើត ខែ ផល្គុន ឆ្នាំ ម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០២៦

# សេចក្ដីជូនដំណឹង (លើកទី២)
## ស្ដីពី
## ការអញ្ជើញចូលរួមពិគ្រោះថ្លៃ
## លើការបំពាក់ប្រព័ន្ធកាមេរ៉ាសុវត្ថិភាព (CCTV Camera)
## នៅអគាររដ្ឋបាល និងច្រកទ្វារចេញ-ចូលនៃចំណតផែពហុបំណង TS៣

កំពង់ផែស្វយ័តភ្នំពេញ សូមជូនដំណឹងដល់បណ្ដាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា កំពង់ផែស្វយ័តភ្នំពេញនឹងដាក់ឱ្យពិគ្រោះថ្លៃជាសាធារណៈលើការបំពាក់ប្រព័ន្ធកាមេរ៉ាសុវត្ថិភាព (CCTV Camera) របស់កំពង់ផែស្វយ័តភ្នំពេញ។

កំពង់ផែស្វយ័តភ្នំពេញ បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមពិគ្រោះថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្ម កំពង់ផែស្វយ័តភ្នំពេញ ដែលមានអាសយដ្ឋានអគារលេខ៦៤៩ វិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញចាប់ពីថ្ងៃទី..២៤......ខែ.កុម្ភៈ......ឆ្នាំ២០២៦ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទំនាក់ទំនងលេខ ០១០ ៤៤៤ ៦៤១)។

កាលបរិច្ឆេទឈប់ទទួលពាក្យសំណើពិគ្រោះថ្លៃនៅវេលាម៉ោង.១៤:៣០.នាទី ថ្ងៃទី...៣...ខែ.មីនា.....ឆ្នាំ២០២៦។

ការបើកសំណើពិគ្រោះថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ **វេលាម៉ោង** ១៤:៣០...នាទី ថ្ងៃទី...៣.....ខែមីនា.....ឆ្នាំ២០២៦។

ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់សំណើពិគ្រោះថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាស ដែលមានបំណងចូលរួមពិគ្រោះថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារពិគ្រោះថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការពិគ្រោះថ្លៃនេះ។

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ជួន សុខេម**